# យុត្តិធម៌ត្រូវបានពន្យារពេលអស់រយៈពេលយ៉ាងយូរ

**ដោយ អាលីហ្សាប៉ែត បេកឃឺ**

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

កាលពីសប្តាហ៍មុន ប៉ូលីសបានធ្វើដំណើរមកដល់ផ្ទះវីឡាមួយនៅទីក្រុងភ្នំពេញ និងបានចាប់ខ្លួន អៀង សារី និងប្រពន្ធគាត់ អៀង ធីរិទ្ធ ដោយបានពន្យល់ពីនីតិវិធីនៃការចាប់ខ្លួនតាមផ្លូវច្បាប់ដល់មេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ទាំងពីរនេះ ។

វាមានរយៈពេលសាមសិបឆ្នាំហើយ ចាប់តាំងពីរបប«វាលពិឃាត»ដ៏ល្បីល្បាញនេះបានដួលរំលំផុតទៅ ដោយបានឆក់យកអាយុជីវិតប្រជាជនកម្ពុជាប្រមាណ មួយលានប្រាំពីរសែននាក់ទៅជាមួយផងដែរ ។ ប៉ុន្តែ ក្នុងរយៈពេលសាមសិបឆ្នាំកន្លងមកនេះ មិនមានជនណាម្នាក់ត្រូវបានវិនិច្ឆ័យទោសសម្រាប់ឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅមួយដែលប្រឆាំងនឹងមនុស្សជាតិនេះនៅឡើយទេ ។

ប៉ុល ពត ដែលជាមេដឹកនាំខ្មែរក្រហម បានស្លាប់ទៅក្នុងនាមជាមនុស្សដែលមានសេរីភាពម្នាក់កាលពីឆ្នាំ១៩៩៨ ។ អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេស និង អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសង្គមកិច្ច ដែលអ្នកទាំងពីរសុទ្ធតែជាអ្នកសហការដ៏ជិតស្និទ្ធិនឹង ប៉ុល ពត បានរស់នៅក្នុងសង្គមកម្ពុជាដោយបើកចំហរ ក្រោមព្រះរាជក្រឹត្យលើកលែងទោសដែលផ្តល់ឲ្យកាលពីឆ្នាំ១៩៩៦ ។ យើងរំពឹងទុកថា ក្នុងចំណោមអ្នកទាំងពីរច្បាស់ជាមានម្នាក់នឹងលើកឡើងពីព្រះរាជក្រឹត្យលើកលែងទោសនេះនៅក្នុងអង្គជំនុំជម្រះក្តីសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរបស់ពួកគេជាមិនខាន ។

អៀង សារី និង អៀង ធីរិទ្ធ គឺជាមេដឹកនាំខ្មែរក្រហមក្នុងចំណោមមេដឹកនាំខ្មែរក្រហមទាំងប្រាំរូបដែលត្រូវបានចាត់ទុកថា មានការទទួលខុសត្រូវខ្ពស់សម្រាប់ដំណើរវាលពិឃាតនៅក្នុងប្រទេសកម្ពុជា ។ មេដឹកនាំខ្មែរក្រហមទាំងប្រាំរូបនេះសុទ្ធតែនៅរស់រានមានជីវិត និងត្រូវនាំមកវិនិច្ឆ័យទោសដោយតុលាការពិសេសមួយដែលទទួលបានការឧបត្ថម្ភគាំទ្រដោយអង្គការសហប្រជាជាតិ ។ អង្គជំនុំជម្រះក្តីនេះនឹងចាប់ផ្តើមបើកអង្គសវនាការដំបូងរបស់ខ្លួននៅក្នុងសប្តាហ៍នេះ ។

ប៉ុន្តែ   អង្គជំនុំជម្រះនេះហាក់បីដូចជាបានកើតឡើងយឺតពេលបន្តិចទៅហើយ ។   និទ្ទណ្ឌភាពដែលមានអាយុកាលជាច្រើនទសវត្សរ៍នេះបានបង្កឲ្យមានភាពឈឺចាប់   ការបាត់បង់ជីវិត   និងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរមួយដែលប៉ះពាល់ដល់ប្រព័ន្ធច្បាប់  និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ។

ខ្ញុំបានរាយការណ៍ពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម   និងវត្តមាននៅប្រទេសកម្ពុជាអស់រយៈពេលពីរសប្តាហ៍នៅក្នុងរបបនេះ ។   ប៉ុន្មានឆ្នាំបន្ទាប់មកទៀតខ្ញុំបានភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់មេដឹកនាំខ្មែរក្រហមដែលអាចគេចផុតពីការផ្តន្ទាទោស ។

ជាក់ស្តែង   មានភស្តុតាងជាច្រើនបាននៅសេសសល់ដែលអាចធ្វើការចោទប្រកាន់មេដឹកនាំខ្មែរក្រហមទាំងនេះ ។ ប៉ុន្តែ នៅថ្ងៃចុងបញ្ចប់នៃសង្គ្រាមត្រជាក់ ប្រទេសចិន និងសហរដ្ឋអាមេរិក ត្រូវការឲ្យខ្មែរក្រហមធ្វើការប្រឆាំងនឹងសហភាពសូវៀត ។ ក្រោយពីរបបខ្មែរក្រហមនេះបានរលត់ផុតទៅ របបគ្រប់គ្រង ហ៊ុន សែន ដែលជាអតីតមេដឹកនាំខ្មែរក្រហមថ្នាក់ទាបម្នាក់ បានប្រឆាំងមិនយល់ព្រមបង្កើតឲ្យមានអង្គជំនុំជម្រះក្តីខ្មែរក្រហមដោយនិយាយថា វាមិនមានប្រយោជន៍អ្វីទេក្នុងការជីកកកាយដំបៅចាស់នោះ ។

ប៉ុន្តែវត្ថុបំណងចុងក្រោយបង្អស់ដែល ហ៊ុន សែន ចង់បាននោះគឺ ការវិនិច្ឆ័យទោសដែលប្រកបដោយយុត្តិធម៌ ។ របបគ្រប់គ្រងរបស់ ហ៊ុន សែន បានកសាងអំណាច និងទ្រព្យសម្បត្តិរបស់ខ្លួនដោយមិនអើពើចំពោះបញ្ហាយុត្តិធម៌  និងនីតិច្បាប់ ។

កេរ្តិ៍តំណែលនៃការខ្វះខាតនីតិច្បាប់នេះ   នឹងបង្កឲ្យមានផលវិបាកក្នុងការផ្តល់យុត្តិធម៌សម្រាប់អង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម   ហើយវានឹងផ្តល់ផលវិបាកកាន់តែខ្លាំងឡើងក្នុងការកែប្រែយុត្តិធម៌នេះឲ្យក្លាយជាភាពរីកចំរើនសម្រាប់សង្គមជាតិកម្ពុជា ។

នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ   យុត្តិធម៌មានតែសម្រាប់អ្នកដែលមានអំណាចខ្ពង់ខ្ពស់តែប៉ុណ្ណោះ ។   អ្នកត្រួតពិនិត្យជាតិ   និងអន្តរជាតិបានកត់ត្រាករណីជាច្រើនដែលមេធាវីទទួលយកសំណូកជាប្រាក់ដុល្លារយ៉ាងច្រើនសន្ធឹកសន្ធាប់មុននឹងចៅក្រមចេញសាលក្រម ។   អ្នកប្រឆាំងផ្នែកនយោបាយជាមួយនឹងរាជរដ្ឋាភិបាលត្រូវបានសម្លាប់   ចំណែកឯឃាតករសម្លាប់មនុស្សវិញមិនដែលត្រូវបានចាប់

ខ្លួនឡើយ ។ លើសពីនេះ មន្ត្រីប៉ូលីសបានរកវិធីសាស្ត្រពន្យល់ពីមូលហេតុដ៏ល្អចំពោះបញ្ហាដែលកើតមានចំពោះក្មេងស្រី និងក្មេងប្រុសរបស់កម្ពុជាដែលត្រូវបានលក់ទៅឲ្យបុរសជនជាតិបរទេស ។

ភីលូជ ណាលី នាយកអង្គការលីកាដូដែលជាអង្គការសិទ្ធិមនុស្សមួយបានចងក្រងឯកសារស្តីពីអំពើហិង្សាជាច្រើនបែបដែលកើតមាននៅក្នុងសង្គមកម្ពុជាបានមានប្រសាសន៍ថា «ខ្ញុំគិតថា ប្រទេសកម្ពុជាមានមធ្យោបាយជាច្រើនក្នុងការសម្រេចបាននូវយុត្តិធម៌» ។

តុលាការកាត់ទោសខ្មែរក្រហម គឺអនុវត្តទៅតាមប្រព័ន្ធច្បាប់កម្ពុជាដែលនឹងត្រូវពង្រឹងទៅតាមបទដ្ឋានអន្តរជាតិ ហើយមេធាវី និងចៅក្រមភាគច្រើនមានសញ្ជាតិជាជនជាតិកម្ពុជា ។ មានតែធ្វើដូច្នេះទេ ទើបរាជរដ្ឋាភិបាលកម្ពុជាយល់ព្រមឲ្យបង្កើតមានអង្គជំនុំជម្រះក្តី ។

រ៉ូប៊ឺត ពើទីត សហព្រះរាជអាជ្ញាអន្តរជាតិ យល់ឃើញថា ច្បាប់កម្ពុជា«មានព័ត៌មានលម្អិតតិចតួចណាស់» ។ ជាមួយគ្នានេះ លោកមានការព្រួយបារម្ភពីទស្សនៈយល់ឃើញពីដំណើរការនៃអង្គជំនុំជម្រះក្តីនេះនៅក្នុងប្រទេសកម្ពុជា ។ ដោយសារតែតុលាការនេះនឹងធ្វើការវិនិច្ឆ័យទោសតែមេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិត ប្រជាជនកម្ពុជានឹងមិនដឹងថា តើនរណាជាអ្នកសម្លាប់បងប្អូនសាច់ញាតិរបស់គេទេ ហើយប្រជាជនកម្ពុជាក៏នឹងមិនទទួលបាននូវសំណងថ្លៃខូចខាតអ្វីដែរ ។

អេង រ៉ូឡែន អតីតអគ្គរាជទូតកម្ពុជាប្រចាំសហរដ្ឋអាមេរិកបាននិយាយថា «តុលាការកាត់ទោសខ្មែរក្រហមនឹងមិនផ្តន្ទាទោសជនដែលបានសម្លាប់ឪពុកម្តាយ បងស្រីប្រាំនាក់ និងបងប្រុសពីរនាក់របស់ខ្ញុំទេ» ។ «យ៉ាងហោចណាស់ តុលាការនេះនឹងជួយឲ្យយុវជនជំនាន់ក្រោយរបស់កម្ពុជាយល់ពីប្រវត្តិសាស្ត្រក្នុងប្រទេសខ្លួន» ។

ប្រជាជនកម្ពុជាដែលកើតនៅក្នុងរបបខ្មែរក្រហមទំនងជាយល់ស្របនឹងគំនិតនេះ ។ អ្នកទាំងនេះយល់ថាមានភាពជាប់ពាក់ព័ន្ធគ្នារវាងអំពើពុករលួយ ដែលកើតមានឡើងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គេជាមួយនឹងភាពស្ងប់ស្ងាត់ និងការពិត ហើយនៅខ្វះខាតចំពោះអ្វីដែលពួកគេបានដឹងពីរបបខ្មែរក្រហម ។

សេង សូលីន និស្សិតផ្នែកគណនេយ្យរបស់មហាវិទ្យាល័យដ៏ល្បីល្បាញក្នុងស្រុកមួយ បានប្រាប់ខ្ញុំថា «ប្រជាជនខ្មែរត្រូវតែយល់ដឹងពីអ្វីដែលត្រូវ និងអ្វីដែលខុស ។ វាចាប់ផ្តើមកើតចេញពីសំណួរមួយដែលសួរថា តើនរណាជាអ្នកបង្កឲ្យមានអំពើប្រល័យពូជសាសន៍លើជនជាតិខ្មែរ ប៉ុល ពត, អៀង សារី ឬក៏ ខៀវ សំផន»?

មិត្តភក្តិរបស់នាងឈ្មោះ ឡេង ជីវតនា ជានិស្សិតផ្នែកគណនេយ្យ បាននិយាយថា តុលាការដែលជោគជ័យ«នឹងនាំមកនូវយុត្តិធម៌ដល់ប្រទេសកម្ពុជា ដើម្បីឲ្យពិភពលោកបានឃើញ ដូច្នេះវាទាមទារឲ្យមានការវិនិយោគទុនពីសំណាក់សហគមន៍អន្តរជាតិបន្ថែមទៀត» ។

ផ្ទុយទៅវិញ ការវិនិយោគទុនពីសំណាក់សហគមន៍អន្តរជាតិកំពុងតែថយចុះ ។ ក្នុងសន្និសីទកាសែតសម្រាប់អ្នកវិនិយោគទុនអន្តរជាតិដែលធ្វើឡើងកាលពីពេលថ្មីៗនេះ ការវិនិយោគទុនគឺគ្រាន់តែជាបន្ទប់ទទេរមួយតែប៉ុណ្ណោះ ។ ពាក្យសម្តីមួយឃ្លាបាននិយាយថា ៈ ប្រទេសកម្ពុជាសំបូរទៅដោយដីនៅទំនេរ និងមានថ្លៃពលកម្មថោក ។

យ៉ាងណាមិញ ប្រទេសកម្ពុជាកំពុងតែរីកចំរើន ។ វិស័យសេដ្ឋកិច្ចបានកើនឡើងក្នុងអត្រា១០ភាគរយក្នុងមួយឆ្នាំ សំណង់អគារខ្ពស់ៗកំពុងតែរីកដុះដាលនៅក្នុងទីក្រុង ។ កន្លែងវាយហ្គោល និងសួនសត្វត្រូវបានគ្រោងនឹងបង្កើតនៅតាមកោះដែលស្ថិតនៅភាគខាងត្បូងនៃប្រទេស ។ លើសពីនេះ រ៉ែប្រេងត្រូវបានរកឃើញ ហើយមិនយូរប៉ុន្មានយើងនឹងឃើញគ្រឿងចក្របូមយកប្រេងនៅពាសពេញផ្ទៃទឹកសមុទ្ររបស់កម្ពុជានៅតាមដងឈូងសមុទ្រសៀមជាមិនខាន ។

ប៉ុន្តែ ទ្រព្យដ៏ច្រើនសន្ធឹកសន្ធាប់ថ្មីនេះ នឹងធ្លាក់ចូលក្នុងហោប៉ៅរបស់មនុស្សមួយក្រុមតូចដែលកាន់កាប់អំណាចក្នុងជួររាជរដ្ឋាភិបាល ។ ជនទាំងនោះបានកាប់បំផ្លាញព្រៃឈើប្រមាណមួយភាគបីនៃព្រៃឈើទាំងអស់ បង្ខំប្រជាកសិករជាច្រើននាក់ឲ្យចាកចេញពីដីដែលពួកគេកំពុងរស់នៅ ដើម្បីយកដីទាំងនោះមកដាំដំណាំ កៅស៊ូ ដូងប្រេង និងដើមចន្ទី ហើយបានបង្ខំឲ្យប្រជាជនក្រីក្រចាកចេញពីផ្ទះសម្បែងរបស់គេដើម្បីយកទីតាំងទាំងនោះមកសាងសង់ជាសំណង់អគារធំៗ

ខណៈពេលដែលកសិករ និងប្រជាជនជនបទក្រីក្របានព្យាយាមដាក់ពាក្យបណ្ដឹងរកយុត្តិធម៌នៅចំពោះមុខតុលាការ ពួកគេទាំងអស់តែងតែក្លាយជាអ្នកចាញ់ក្ដីរហូត ។ នេះគឺជាវដ្ដនៃនិទ្ទណ្ឌភាពដែលមិនអាចកាត់ផ្ដាច់បាន ។

ប្រសិនបើខ្មែរក្រហមអាចគេចផុតពីការទទួលខុសត្រូវលើការសម្លាប់មនុស្សជាងពីរលាននាក់នោះ មានន័យថា អ្នកដែលប្រព្រឹត្តដូចខ្មែរក្រហមនឹងគិតថាខ្លួនជាមនុស្សដែលអាចគេចផុតពីសំណាញ់ច្បាប់បាន ។ ប៉ុន្តែ ប្រសិនបើតុលាការកាត់ទោសខ្មែរក្រហមទទួលបានជោគជ័យក្នុងការផ្ដន្ទាទោសមេដឹកនាំខ្មែរក្រហមប៉ុន្មាននាក់នេះ នោះការគេចផុតពីសំណាញ់ច្បាប់នឹងចាប់ផ្ដើមប្រែប្រួលជាមិនខាន ។